**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខ: ៥០២លស./គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦

## គោរពជូន

## ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ បាត់ដំបង សៀមរាប និងខេត្តប៉ៃលិន

**កម្មវត្ថុ** ៖ អំពីការគាំទ្រអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គមលើផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការរបស់អង្គការវ៉ាឆា។

**យោង** ៖ -លិខិតលេខ ១១០លស/គ.ជ.អ.ប ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គមនៅស្រុកគោលដៅ៥៤ នៃ១៤ខេត្ត។

-អនុស្សាណៈយោគយល់រវាងលេខាធិការដ្ឋានគជ.អ.ប និងអង្គការវ៉ាឆា ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម។

-ផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១៦-២០១៨។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា ក្នុងការអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គមឆ្នាំ២០១៦នេះ គឺអនុវត្តលើស្រុកគោលដៅសរុបចំនួន៥៤ ដែលក្នុងនោះ លេខាធិការដ្ឋានគ.ជ.អ.ប បានវិភាជន៍ថវិកាដើម្បីគាំទ្រការអនុវត្តការងារគណនេយ្យភាពសង្គមផ្នែកផ្គត់ផ្គង់ចំនួន៤០ ស្រុក ក្នុងខេត្តចំនួន១៣។ ដោយឡែក ១៤ស្រុកគោលដៅទៀតរួមមាន ៣ស្រុកនៅខេត្តបន្ទាយមានជ័យ ៣ស្រុកនៅខេត្តបាត់ដំបង ៧ស្រុកនៅខេត្តសៀមរាប និង១ស្រុកនៅខេត្តប៉ៃលិន អង្គការវ៉ាឆា នឹងធ្វើការគាំទ្រផែនការសកម្មភាព ថវិកា និងបច្ចេកទេសទាំងពីរផ្នែក គឺផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ ហើយលេខាធិការដ្ឋានគ.ជ.អ.ប នឹងសហការគាំទ្រត្រឹមកម្រិតបច្ចេកទេស។

ផ្អែកតាមអនុស្សាណៈយោគយល់គ្នារវាងលេខាធិការដ្ឋានគ.ជ.អ.ប និងអង្គការវ៉ាឆា ចុះនៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ អង្គការវ៉ាឆា បានព្រមព្រៀងគាំទ្រអនុវត្តការងារគណនេយ្យភាពសង្គមនៅក្នុងស្រុកគោលដៅចំនួន២១ ក្នុងខេត្តចំនួន៤ ដោយក្នុងនោះ មានស្រុកចំនួន៧ គឺស្រុកថ្មគោល សង្កែ បាណន់ បវេល ឯកភ្នំ មោងឫស្សី និងស្រុកសំឡូត) ក្នុងខេត្តបាត់ដំបងដែលអង្គការវ៉ាឆា នឹងគាំទ្រអនុវត្តផ្នែកតម្រូវការ ស្របតាមលិខិតលេខ១១០លស/គ.ជ.អ.ប ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៦ ចំណែកស្រុកចំនួន ១៤ ទៀត អង្គការវ៉ាឆា នឹងធ្វើការគាំទ្រទាំងពីរផ្នែកគឺផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ ដូចខាងក្រោម៖

- ខេត្តបន្ទាយមានជ័យ(៣ស្រុក) ៖ ស្រុកព្រះនេត្រព្រះ ស្រុកអូរជ្រៅ និងស្រុកម៉ាឡៃ
- ខេត្តសៀមរាប(៧ស្រុក) ៖ ស្រុកអង្គរជុំ ស្រុកប្រាសាទបាគង ស្រុកសូទ្រនិគមន៍ ស្រុកស្រីស្នំ ស្រុកអង្គរធំ ស្រុកបន្ទាយស្រី និងស្រុកស្វាយលើ។
- ខេត្តបាត់ដំបង(៣ស្រុក) ៖ ស្រុកសំពៅលូន ស្រុកគាស់ក្រឡ និងស្រុករុក្ខគិរី
- ខេត្តប៉ៃលិន(១ស្រុក) ៖ ស្រុកសាលាក្រៅ។

សូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបបន្ថែមទៀតថា៖ ទោះបីជាប្រភពថវិកាសម្រាប់ការអនុវត្តផ្សេងគ្នា ប៉ុន្តែដើម្បីធានាបាននូវដំណើរការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម ឲ្យទទួលបាននូវលទ្ធផលល្អប្រសើរដូចគ្នាទៅនឹងបណ្តាខេត្ត និងស្រុកផ្សេងទៀត។ ដូច្នេះលេខាធិការដ្ឋានគ.ជ.អ.ប បានជួបពិភាក្សាជាមួយអង្គការវ៉ាឆាក្នុងការរៀបចំ

ផែនការសកម្មភាពប្រចាំឆ្នាំរួមគ្នាមួយ ដើម្បីកំណត់នូវសកម្មភាពមួយចំនួនគាំទ្រថវិកាដោយអង្គការវ៉ាឆាសម្រាប់ផ្នែកផ្គត់ផ្គង់ជាពិសេសថ្នាក់ខេត្ត និងថ្នាក់ស្រុក ដូចខាងក្រោម៖

❖ រដ្ឋបាលខេត្ត (មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស)៖

១.ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម

២.បណ្តុះបណ្តាល និងបោះពុម្ពកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4C) និង

៣.ចុះតាមដានត្រួតពិនិត្យ និងគាំទ្រដំណើរការអនុវត្តការងារគណនេយ្យភាពសង្គមថ្នាក់មូលដ្ឋាន។

❖រដ្ឋបាលស្រុក៖

១.ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមដល់គ្រប់ឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សា។

២.បណ្តុះបណ្តាលសៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិការគណនេយ្យភាពសង្គមសម្រាប់ផ្នែកផ្គត់ផ្គង់ និងប្រព័ន្ធទិន្នន័យតាមដាន និងត្រួតពិនិត្យ ដល់គ្រប់ឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សា និងមន្ត្រីបង្គោលស្រុក(នាយករដ្ឋបាល ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិនិងការិយាល័យស្រុក)។

៣.ចុះប្រមូល បញ្ចូលទិន្នន័យ និងបោះពុម្ពព័ត៌មានសម្រាប់បិទផ្សាយ (Post-On)

៤.ដំណើរការបិទផ្សាយ និងចុះតាមដានការផ្តល់ព័ត៌មាន និង

៥.កិច្ចប្រជុំឆ្លុះបញ្ចាំង អំពីដំណើរការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម។

ចំពោះនីតិវិធីដើម្បីអាចអនុវត្តសកម្មភាពទាំងអស់ខាងលើបាន រដ្ឋបាលខេត្ត និងរដ្ឋបាលស្រុកត្រូវសហការពិភាក្សាជាមួយតំណាងអង្គការវ៉ាឆា ប្រចាំតំបន់គោលដៅ ដើម្បីរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដែលការប៉ាន់ស្មានថវិកាលម្អិតលើសកម្មភាពនីមួយៗ គឺត្រូវផ្អែកលើចំនួនថវិកាដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី៣ នៃអនុស្សារណៈយោគយល់គ្នា និងស្របនឹងគោលការណ៍ហិរញ្ញវត្ថុរបស់អង្គការវ៉ាឆា (ឧ.ការចំណាយលើបេសកកម្ម ឬការធ្វើដំណើរចូលរួមវគ្គបណ្តុះបណ្តាលជាដើម)។ លេខាធិការដ្ឋាន គ.ជ.អ.ប សូមលើកទឹកចិត្តដល់រដ្ឋបាលខេត្ត រដ្ឋបាលស្រុកក្នុងការផ្តល់កិច្ចសហការល្អជាមួយអង្គការដៃគូអនុវត្តទាំងអស់ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម។

សូមជូនភ្ជាប់មកជាមួយនូវ អនុស្សារណៈយោគយល់គ្នារវាងលេខាធិការដ្ឋានគ.ជ.អ.ប និងអង្គការវ៉ាឆា និងឯកសារពាក់ព័ន្ធមួយចំនួន។

អាស្រ័យហេតុនេះ សូមឯកឧត្តមអភិបាលខេត្ត មេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

<u>ចម្លងជូន៖</u>

-គ.គ.អ.ស I-SAF PSC "ជូនជ្រាប"

-រដ្ឋបាលខេត្តបន្ទាយមានជ័យ បាត់ដំបង សៀមរាប និងខេត្តប៉ៃលិន

-រដ្ឋបាលស្រុកគោលដៅ

-ទីប្រឹក្សាPPMA និងទីប្រឹក្សាDMA

-អង្គការវ៉ាឆា "ដើម្បីសហការអនុវត្ត"

-ឯកសារកាលប្បវត្តិ